# ឧបករណ៍ផ្សព្វផ្សាយការសំរេចសាថ្មី៖ ដំណាក់កាលទី 2

ឧបករណ៍នេះ បំរើជាមគ្គុទ្ទេសក៍នៃការប្រស្រ័យទាក់ទង និងផ្តល់ធនធានដៃគូ ដើម្បីគាំទ្រសមាជិក MassHealth ឆ្លងកាត់ការចុះឈ្មោះសាថ្មីរបស់គេ។

## មាតិការឿង


សេចក្តីផ្តើម និងសារៈសំខាន់នៃការប្រស្រ័យទាក់ទង ..... 2

សារៈសំខាន់នៃការប្រស្រ័យទាក់ទង ..... 2

ស្រោមសំបុត្រខៀវ និង ព័ត៌មានសំខាន់ៗផ្សេងទៀត ផ្ញើមកពី MassHealth ..... 3

ព័ត៌មានសំខាន់ៗផ្សេងទៀត ផ្ញើមកពី MassHealth ..... 4

ព័ត៌មានសំរាប់ប្រជាជនជាក់លាក់ ..... 4

ដំណាក់កាលទី 2 សំខាន់ និងសារបន្ថែម ..... 4

សារបន្ថែម៖ ..... 5

របៀបចុះឈ្មោះសាថ្មី ..... 6

ការឃោសនា "គ្រួសាររបស់អ្នក។ សុខភាពរបស់អ្នក។" ..... 6

ធនធានការចុះឈ្មោះសាថ្មី សំរាប់ដៃគូ និងអ្នករួមធុរៈ ..... 6

ខិត្តប័ណ្ណ, បដា, និងសំភារៈដែលសមាជិកផ្សេងទៀតប្រឈមមុខ ..... 7

## សេចក្តីផ្តើម និងសារៈសំខាន់នៃការប្រស្រ័យទាក់ទង

នៅក្នុងខែមីនា ឆ្នាំ 2020 រដ្ឋាភិបាលសហព័ន្ធបានប្រកាស អាសន្នសុខភាពសាធារណៈ (Public Health Emergency, PHE) ដោយព្រោះជំងឺ COVID-19 រាតត្បាត។ ជាការឆ្លើយតបចំពោះ PHE និងប្រកាន់ខ្ជាប់ចំពោះការតម្រូវនៃសហព័ន្ធ MassHealth បានរៀបចំឲ្យមាននីតិវិធីការពារ ដែលបានការពារការរ៉ាប់រង របស់សមាជិក MassHealth អំឡុងពេលចប់ភាពអាសន្ន COVID-19។

រដ្ឋាភិបាលសហព័ន្ធ នឹងបញ្ចប់ការតម្រូវ បន្តការ៉ាប់រងនៅថ្ងៃទី 1 ខែមេសា 2023 ជាពេល MassHealth នឹងត្រឡប់ទៅនីតិវិធីចុះឈ្មោះសាថ្មី ជាធម្មតារបស់យើងវិញ។ នៅពេលនេះ MassHealth នឹងត្រូវចុះឈ្មោះសាថ្មី សំរាប់ការ៉ាប់រងសុខភាពរបស់សមាជិកទាំងអស់ ដើម្បីឲ្យប្រាកដថាគេនៅតែមានសិទ្ធិទទួល អត្ថប្រយោជន៍បច្ចុប្បន្នរបស់គេ។ ការចុះឈ្មោះសាថ្មីទាំងនេះ នឹងប្រព្រឹត្តិក្នុងពេល 12 ខែ ខាងមុខ ចាប់តាំងពីខែមេសា 2023 ទៅដល់ខែមេសា 2024។ នេះមានសេចក្តីថាសមាជិកអាចទទួលទំរង់បំពេញចុះឈ្មោះសាថ្មីរបស់គេ តាមប្រៃសណីយ៍ នៅពេលណាមួយ អំឡុងរយៈពេលមួយឆ្នាំនេះ។

ដើម្បីកាត់បន្ថយ ចំនួនសមាជិកដែលមានសិទ្ធិទទួល ដែលបាត់បង់ការ៉ាប់រងរបស់គេ ម្ល៉ោះហើយ MassHealth កំពុងតែធ្វើការជាមួយ Massachusetts Health Connector, Health Care For All និងដៃគូផ្សេងៗទៀត ដើម្បីធ្វើឲ្យប្រាកដថាសមាជិកដឹងរបៀប ចុះឈ្មោះសាថ្មី សំរាប់ការ៉ាប់រងរបស់គេ និងដឹងជំរើស ការ៉ាប់រងសុខភាពផ្សេងទៀតដែលអាចផ្គត់ផ្គង់បាន បើសិនជាត្រូវការ។

MassHealth កំពុងតែប្រស្រ័យទាក់ទងទៅសមាជិក ជាពីរដំណាក់កាលៈ

- ***ដំណាក់កាលទី 1៖ ជំរាបដំណឹង៖ រៀបចំសារ់ប់ការចុះឈ្មោះសាថ្មី នៃសមាជិក MassHealth ទាំងអស់***
    - MassHealth កំពុងតែធ្វើការជាមួយអ្នករួមធុរៈ និងដៃគូផ្សេងៗទៀត ដើម្បីធ្វើឲ្យប្រាកដថាសមាជិកដឹងរបៀបជៀសវាង ចន្លោះក្នុងការ៉ាប់រង នៅពេលការចុះឈ្មោះសាថ្មីចាប់ផ្តើម។
- ***ដំណាក់កាលទី 2៖ អប់រំ៖ អប់រំសមាជិក អំពីរបៀបចុះឈ្មោះសាថ្មី សំរាប់ការ៉ាប់រងរបស់គេ***
    - MassHealth និងដៃគូរបស់ខ្លួន នឹងផ្សព្វផ្សាយផ្ទាល់ទៅសមាជិក នៅពេលគេត្រូវបានជ្រើសរើស សំរាប់ការចុះឈ្មោះសាថ្មី ដើម្បីធ្វើឲ្យប្រាកដ ថាគេបំពេញការចុះឈ្មោះសាថ្មីរបស់គេ និងដឹងជំរើសរបស់គេ សំរាប់ការ៉ាប់រងសុខភាពអាចផ្គត់ផ្គង់បាន (បើសិនពាក់ព័ន្ធ)។

*ឧបករណ៍នេះ នឹងជួយអ្នករួមធុរៈ និងដៃគូ ដើម្បីអប់រំ និងផ្សព្វផ្សាយទៅសមាជិករបស់គេ* ***អំឡុងពេលដំណាក់កាលទី 2*** *។*

## សារៈសំខាន់នៃការប្រស្រ័យទាក់ទង

នៅបច្ចុប្បន្ននេះ មាននីតិវិធីការពារ ដែលអនុញ្ញាតឲ្យសមាជិកទាំងអស់ ដើម្បីទុកការ៉ាប់រង MassHealth របស់គេ រហូតដល់ថ្ងៃទី 1 ខែមេសា 2023។ ចាប់ផ្តើមនៅថ្ងៃទី 1 ខែមេសា 2023 MassHealth ត្រូវចុះឈ្មោះសាថ្មី សមាជិកទាំងអស់។ ការចុះឈ្មោះសាថ្មីទាំងនេះ នឹងប្រព្រឹត្តិក្នុងពេល 12 ខែ ខាងមុខ។ នីតិវិធីការសំរេចសាថ្មីនេះ នឹងជាផ្លាស់ប្តូរសុខភាពមួយធំបំផុត ចាប់តាំងពីការបើកចុះឈ្មោះដំបូងនៃ ក្រឹត្យថៃទាំអាចផ្គត់ផ្គង់បាន និងការពង្រីក Medicaid។ សមាជិកត្រូវដឹង ដើម្បីរំពឹងអ្វីខ្លះ និងរបៀបទុកការ៉ាប់រងសុខភាពរបស់គេ នៅពេល MassHealth ត្រឡប់ទៅវិធីចុះឈ្មោះសាថ្មី ជាធម្មតារបស់យើងវិញ។ សមាជិកភាគច្រើន នឹងនៅតែមានសិទ្ធិទទួល MassHealth ដដែល ឬមានសិទ្ធិទទួលប្រាក់ឧបត្ថម្ភ ដែលនឹងអនុញ្ញាតឲ្យគេទទួលការ៉ាប់រងអាចផ្គត់ផ្គង់បាន តាមរយៈ Health Connector ឬប្រភពផ្សេងទៀត។

MassHealth បានប្តូរផ្តាច់ ដើម្បីប្រស្រ័យទាក់ទងឲ្យមានប្រសិទ្ធិភាព ជាមួយសមាជិក និងបានបង្កើតក្រុមការងារ ឆ្លងកាត់ភ្នាក់ងារ ដើម្បីជួយបង្កើតយុទ្ធសាស្រ្ត ការប្រស្រ័យទាក់ទងថែមទៀត និងសំភារៈនានា សំរាប់សមាជិក ដែលអាចនឹងពិបាកទាក់ទង ឬមានការសំរេចសាថ្មីស្មុគស្មាញ រួមទាំងសមាជិកកំពុងជួបប្រទះ ភាពគ្មានលំនៅ, សមាជិកដែលពិការ, សមាជិកអាយុ 65 ឆ្នាំ ឬ ចាស់ជាង, ប្រជាជនអន្តោប្រវេសន៍, ព្រមទាំងក្មេងៗ និងគ្រួសារ។

ការប្រស្រ័យទាក់ទងរបស់ MassHealth ត្រូវបានពង្រីក ដើម្បីបញ្ចូល**ទាំងជាពាក្យ និងសមត្ថភាពអ៊ីមែល**។ សមាជិកដែលបានចែកចាយ លេខទូរស័ព្ទដៃរបស់គេ និង/ឬ អ៊ីមែលជាមួយ MassHealth នឹងទទួលពាក្យ និង/ឬ អ៊ីមែល ប្រាប់គេឲ្យដឹងថា ទំរង់បំពេញចុះឈ្មោះសាថ្មីរបស់គេនឹងមកឆាប់ៗ។ ទំរង់បំពេញចុះឈ្មោះសាថ្មី នឹងបានផ្ញើទៅសមាជិកក្នុង**ស្រោមសំបុត្រខៀវ**។

ឧបករណ៍នេះ បំរើជាមគ្គុទ្ទេសក៍នៃការប្រស្រ័យទាក់ទង និងផ្តល់ធនធាន ដើម្បីគាំទ្រសមាជិក អំឡុងពេលចុះឈ្មោះសាថ្មីរបស់គេ។

## ស្រោមសំបុត្រខៀវ និង ព័ត៌មានសំខាន់ៗផ្សេងទៀត ផ្ញើមកពី MassHealth

នៅក្នុងនីតិវិធីការសំរេចសាថ្មី MassHealth នឹងផ្ញើចេញសំបុត្រចុះឈ្មោះសាថ្មី ទៅសមាជិកទាំងអស់ ក្នុងស្រោមសំបុត្រខៀវ *(មានរូបភាពខាងក្រោម)*។

នៅខាងក្នុងស្រោមសំបុត្រខៀវនិមួយៗ សមាជិកនឹងឃើញមានដូចខាងក្រោមនេះ៖

- សេចក្តីជូនដំណឹងការចុះឈ្មោះសាថ្មីរបស់គេ រួមទាំងកាលកំណត់ នៃការចុះឈ្មោះសាថ្មីរបស់គេ,
- ក្រដាសស៊ក អំពីការចុះឈ្មោះសាថ្មី, និង
- ក្រដាសទំរង់បំពេញចុះឈ្មោះសាថ្មី។




ការណែនាំពេញលេញ សំរាប់អ្នករួមផ្ទះ និងដៃគូ ស្តីពីរបៀបជួយសមាជិក ដែលបានទទួលស្រោមសំបុត្រខៀវ អាចរកឃើញនៅទីនេះ។

### ព័ត៌មានសំខាន់ៗផ្សេងទៀត ផ្ញើមកពី MassHealth

នៅអំឡុងរយៈពេលនេះ **សមាជិកអាចនឹងទទួលព័ត៌មានសំខាន់ៗផ្សេងទៀត ផ្ញើមកពី MassHealth ដែលគេត្រូវតែអាន និងឆ្លើយតប ប្រយោជន៍ដើម្បីរក្សាការរ៉ាប់រងរបស់គេ និងយល់ដឹងអត្ថប្រយោជន៍អ្វីខ្លះ ដែលគេមានសិទ្ធិទទួល។**

សំបុត្រផ្សេងទៀតនេះ នឹងមកដល់ក្នុងស្រោមសំបុត្រស ជាដោយឡែកពីស្រោមសំបុត្រខៀវ ដែលមានការចុះឈ្មោះសាថ្មី។ អាសយដ្ឋានផ្ញើត្រឡប់វិញ អាចនឹងបង្ហាញពាក្យ "Commonwealth of Massachusetts" ឬផ្នែកជាក់លាក់មួយនៃ Commonwealth ដូចជា Health Insurance Processing Center ឬ EDMC។ សមាជិកគួរតែឃ្លាំមើល សំរាប់សំបុត្រអ្វីមួយ ដែលអាចជាមកពី MassHealth និងបើកមើលស្រោមសំបុត្រទាំងអស់។

សំបុត្រព័ត៌មានសំខាន់ៗផ្សេងទៀត អាចនឹងរួមមាន៖

- សំណើសុំព័ត៌មាន
- សំណើសុំការបញ្ជាក់
- សេចក្តីជូនដំណឹង ការចុះឈ្មោះសាថ្មីជាស្វ័យប្រវត្តិ (មិនបាច់ធ្វើអ្វី)
- វិក្កយប័ត្រថ្លៃបង់ធានារ៉ាប់រង
- ការបន្ថែមសំរាប់មនុស្សពេញវ័យ ឬក្មេងពិការ
- ឯកសារផ្សេងៗទៀត

### ព័ត៌មានសំរាប់ប្រជាជនជាក់លាក់

MassHealth បានសំគាល់ឃើញប្រជាជនប្រាំប្រភេទ ដែលអាចនឹងត្រូវការយុទ្ធសាស្ត្រផ្សព្វផ្សាយ និងរៀបចំសារហ្មត់ចត់ ដើម្បីបំពេញការចុះឈ្មោះសាថ្មីរបស់គេ ឲ្យបានជោគជ័យ។ ប្រជាជនទាំងនេះ អាចនឹងត្រូវការផ្សព្វផ្សាយជាបន្ថែមទៀត ពីព្រោះគេពិបាកទាក់ទង មានការចុះឈ្មោះសាថ្មីស្មុគស្មាញ ឬមានពិបាកខ្លាំង ក្នុងការបំពេញការចុះឈ្មោះសាថ្មីរបស់គេ។ MassHealth បានបង្កើតក្រុមការងារមួយ ដើម្បីគាំទ្រសមាជិកឲ្យល្អប្រសើរ ដែលឋិតក្នុងហានិភ័យខ្ពស់ នៃការបាត់បង់ការរ៉ាប់រងរបស់គេ រួមទាំង៖

- មនុស្សពេញវ័យចាស់ៗ (សមាជិក អាយុ 65 ឆ្នាំ និងចាស់ជាង)
- បុគ្គលដែលពិការ
- បុគ្គលកំពុងជួបប្រទះ ភាពអនាល័យ
- បុគ្គលដែលមិនមែនជាពលរដ្ឋ
- ក្មេងៗ គ្រួសារ និងបុគ្គលមានគភ៌

MassHealth បានបង្កើតសំភារៈប្រស្រ័យទាក់ទងសមរម្យ ដើម្បីទាក់ទងទៅប្រជាជនទាំងនេះ និងអង្គការដែលបំរើគេ។

## ដំណាក់កាលទី 2 សំខាន់ និងសារបន្ថែម

អំឡុងពេលដំណាក់កាលទី 2 នេះ MassHealth និងដៃគូរបស់ខ្លួន គួរតែប្រើសារសំខាន់ៗខាងក្រោម ដើម្បីអប់រំសមាជិក អំពីការចុះឈ្មោះសាថ្មីខាងមុខ និងធ្វើឲ្យប្រាកដ ថាគេពុំមានចន្លោះក្នុងការរ៉ាប់រង។

- **កែព័ត៌មានរបស់អ្នកឲ្យទាន់សម័យ ជាមួយ MassHealth។** ធ្វើឲ្យប្រាកដថា MassHealth មានអាសយដ្ឋាន លេខទូរស័ព្ទ និងអ៊ីមែល របស់អ្នកទាន់សម័យបំផុត ប្រយោជន៍កុំឲ្យអ្នកខានទទួលព័ត៌មាន និងសេចក្តីជូនដំណឹងសំខាន់ៗ មកពី MassHealth។
- **អានសំបុត្ររបស់អ្នកទាំងអស់។** MassHealth នឹងផ្ញើទំរង់បំពេញចុះឈ្មោះសាថ្មីរបស់អ្នក ក្នុងស្រោមសំបុត្រខៀវ។ សេចក្តីជូនដំណឹងសំខាន់បន្ថែម ឬសំណើសុំព័ត៌មាន អាចនឹងមកដល់ក្នុងស្រោមសំបុត្រស។

- **ឆ្លើយតបទៅ MassHealth ឲ្យបានមុនកាលកំណត់។** សេចក្តីជូនដំណឹងរបស់អ្នក នឹងមានកាលកំណត់។ ធ្វើឲ្យប្រាកដថាអ្នកបំពេញ និងផ្ញើព័ត៌មានទាំងអស់ដែលត្រូវការ ទៅ MassHealth ឲ្យទាន់កាលកំណត់។

## សារបន្ថែម៖

បើសិនអ្នកគិតថាអ្នកប្រហែលជាពុំមានសិទ្ធិទទួល MassHealth ទេ វាមានជំរើសការធានារ៉ាប់រងសុខភាពផ្សេងទៀត។

**Massachusetts Health Connector៖** អ្នកអាចនឹងមានសិទ្ធិទទួល គំរោងអាចផ្គត់ផ្គង់បាន តាមរយៈ MA Health Connector។ សមាជិកអាចទស្សនា www.mahealthconnector.org/ ឬហៅសេវាអតិថិជន លេខ 1-877- MA ENROLL (1-877-623-7773) ដើម្បីស្វែងយល់ថែមទៀត ឬចុះឈ្មោះក្នុងគំរោងមួយ។ បើសិនអ្នកបាត់បង់ការរ៉ាប់រង MassHealth របស់អ្នក វាគឺជា ព្រឹត្តិការណ៍ជីវិតមានសិទ្ធិទទួល (Qualifying Life Event, QLE)។ នេះមានសេចក្តីថា អ្នកអាចចុះឈ្មោះក្នុងគំរោងមួយ ជាមួយ Health Connector ក្រៅពីរយៈពេលបើកចុះឈ្មោះធម្មតា។

**ការធានារ៉ាប់រងនិយោជកឧបត្ថម្ភ៖** នៅក្នុងរដ្ឋម៉ាស្សាជូសេត្ត មានជាង 70% នៃនិយោជកទាំងអស់ ផ្តល់ជូនការធានារ៉ាប់រងសុខភាព ជាអត្ថប្រយោជន៍មួយ សំរាប់និយោជិតរបស់គេ។ ភាគច្រើននៃនយោជកទាំងនេះ បង់ផ្នែកនៃថ្លៃបង់ធានារ៉ាប់រង និងក៏ផ្តល់ជូនជំរើស នៃគំរោងសុខភាពជាច្រើន។ បើសិននិយោជករបស់សមាជិក ផ្តល់ជូនការធានារ៉ាប់រង គេអាចជ្រើសរើសគំរោងសុខភាព ដែលល្អបំផុតសំរាប់គេ ចេញពីជំរើសដែលបានផ្តល់ជូន។ បើសិនអ្នកអាចទទួល គំរោងសុខភាពនិយោជកឧបត្ថម្ភ នោះការបាត់បង់ការរ៉ាប់រង MassHealth របស់អ្នក ត្រូវបានចាត់ទុកជាព្រឹត្តិការណ៍ជីវិតមានសិទ្ធិទទួល (QLE)។ QLE នឹងបណ្តាលឲ្យមាន រយៈពេលចុះឈ្មោះពិសេស (Special Enrollment Period, SEP) ដែលនឹងអនុញ្ញាតឲ្យអ្នកចុះឈ្មោះ ក្នុងគំរោងនៃនិយោជករបស់អ្នក នៅក្រៅពីរយៈពេលបើកចុះឈ្មោះប្រចាំឆ្នាំ។ ជាទូទៅ SEP គឺមានសំរាប់តែចំនួន 60 ថ្ងៃ ក្រោយពី QLE ម៉្លោះហើយមិនបាច់រង់ចាំ ដើម្បីមើលជំរើសឡើងវិញ ជាមួយនិយោជករបស់អ្នកទេ។

**Medicare Savings Programs៖** កម្មវិធីសន្សំប្រាក់ Medicare (Medicare Savings Programs, MSP) (ពីមុនហៅថាជា MassHealth Senior Buy-In និង Buy-In programs) គឺជាកម្មវិធីនៃរដ្ឋាភិបាលសហព័ន្ធផ្តល់ប្រាក់ ដែលបង់ថ្លៃធានារ៉ាប់រង ការកាត់ថ្លៃ និងរួមធានារ៉ាបរង របស់អ្នកទទួល Medicare មួយចំនួន ឬទាំងអស់ ដែលមានប្រាក់ចំណូលទាប។

**Prescription Advantage៖** កម្មវិធី Prescription Advantage គឺជាកម្មវិធីឱសថមានវេជ្ជបញ្ជា រដ្ឋឧបត្ថម្ភសំរាប់មនុស្សចាស់ៗ និងមនុស្សដែលពិការ និងផ្តល់ជំនួយប្រាក់ ដើម្បីបន្ទាបតម្លៃឱសថមានវេជ្ជបញ្ជារបស់គេ។

**កម្មវិធី Home and Community Based Waivers រួមទាំង Frail Elder Waiver៖** កម្មវិធី មនុស្សចាស់ជរាវៀរបង់ (Frail Elder Waiver, FEW) គឺជាកម្មវិធី MassHealth មួយ ដោយបានពង្រីកប្រាក់ចំណូលសិទ្ធិទទួល បានគ្រប់គ្រងដោយ ការិយាល័យប្រតិបត្តិកិច្ចការចាស់ទុំ (Executive Office of Elder Affairs) ដែលផ្តល់ការគាំទ្រសហគមន៍ សំរាប់អ្នកមូលដ្ឋានរដ្ឋម៉ាស្សាជូសេត្ត មានអាយុ 60 ឆ្នាំ និងចាស់ជាង ដែលបើមិនដូច្នេះទេ ត្រូវការថែទាំនៃមន្ទីរមួយ។ FEW គាំទ្របុគ្គលនានា ដែលមានសេចក្តីត្រូវការផ្សេងៗ ដែលអាចបានជួបជាច្រើន ពីការគាំទ្រតាមផ្ទះ។

**កម្មវិធី Program All-inclusive Care for the Elderly (PACE)៖** កម្មវិធីបញ្ចូលការថែទាំទាំងអស់ សំរាប់ចាស់ទុំ (Program of All-inclusive Care for the Elderly, PACE) គឺបានគ្រប់គ្រងដោយ MassHealth និង Medicare ដើម្បីផ្តល់សេវាទូលំទូលាយ ខាងសុខភាព សង្គម ការកំសាន្ត និងសេវាផាសុកភាព សំរាប់អ្នកចូលរួម ដែលមានសិទ្ធិទទួល។ អ្នកមិនបាច់នៅក្នុង MassHealth ដើម្បីចុះឈ្មោះក្នុង PACE ទេ។

## របៀបចុះឈ្មោះសាថ្មី

កាលណាសមាជិកបានទទួល ស្រោមសំបុត្រខៀវ តាមប្រៃសណីយ៍ គេមានរបៀបមួយចំនួន ដែលគេអាចបញ្ជូនការចុះឈ្មោះសាថ្មីរបស់គេ។

ដើម្បីស្វែងយល់ថែមទៀត ទស្សនា www.mass.gov/how-to/renew-your-masshealth-coverage

## ការឃោសនា "គ្រួសាររបស់អ្នក។ សុខភាពរបស់អ្នក។"

នៅអំឡុងពេលដំណាក់កាលទី 2 នេះ MassHealth កំពុងធ្វើជាដៃគូ ជាមួយ Massachusetts Health Connector និង Health Care For All ដើម្បីជួយអប់រំ និងជំរាបដំណឹងសមាជិក MassHealth ឲ្យផ្តោតលើសហគមន៍ 15 កន្លែង ដែល មានប្រជាជនទូទៅច្រើនបំផុត នៃសមាជិក MassHealth។ MassHealth និងដៃគូរបស់ខ្លួន នឹងខិតខំធ្វើការផ្សព្វផ្សាយទាំងនេះ ជាពីរដំណាក់កាល ដើម្បីផ្តល់ព័ត៌មានទៅបុគ្គល និងសហគមន៍ទាំងឡាយ អំពីនីតិវិធីចុះឈ្មោះសាថ្មី និងផ្តល់ធនធានក្នុងតំបន់ ដើម្បីជួយសមាជិក បំពេញនីតិវិធីចុះឈ្មោះសាថ្មីរបស់គេ ដោយជោគជ័យ។

ការឃោសនាយោងតាមសហគមន៍ នឹងប្រើរបៀបបីយ៉ាងងាយស្រួល ដើម្បីចែកចាយព័ត៌មាន និងធនធាន ជាមួយសមាជិក។

- **ការដើរប្រកាស ពីទ្វារមួយទៅទ្វារមួយ៖** HCFA នឹងជួលអ្នកដើរប្រកាសតាមតំបន់ ដើម្បីចែកចាយសំភារៈ និងធនធាន ជាមួយបុគ្គល និងគ្រួសារទាំងពួង នៅក្នុងសហគមន៍ 15 ដើម្បីជួយគេអំឡុងពេលនីតិវិធីការសំរេចសាថ្មី។
- **សម្បទានជំនួសប្រាក់សំរាប់ អង្គការតាមសហគមន៍ (Community-Based Organizationc, CBO)៖** CBO នឹងបានឲ្យប្រាក់ ដើម្បីធ្វើសកម្មភាពការអប់រំ និងការដឹង នៅក្នុងសហគមន៍ដែលគេបំរើ។ ប្រាក់សម្បទាន នឹងបានឲ្យទៅ CBO ដែលគេបំរើប្រជាជន ក្នុងតំបន់ភូមិសាស្ត្របានប៉ះ ឬដែលគេបំរើប្រជាជនជាក់លាក់ ដូចជាសមាជិកកំពុងជួបប្រទះ ភាពគ្មានលំនៅ ឬមនុស្សចាស់ៗ។
- **Media buy៖** ការផ្សាយលក់ តាមទំរង់ផ្ទិត, ឌីជិតាល់, វិទ្យុ និងទូរទស្សន៍ នឹងបានទិញតាមយុទ្ធសាស្ត្រ ដើម្បីជួយផ្សាយដំណឹង នៃការសំរេចសាថ្មី ជាប្រាំបួនភាសាផ្សេងទៀត *(អង់គ្លេស, អេស្ប៉ាញ៉ុល, ក្រេអូល ខាបវឺឌីន, ក័ទូហ្គី, ក្រេអូល ហៃទី, ខ្មែរ, វៀតណាម, ចិន, និង អារ៉ាប់)* ។

## ធនធានការចុះឈ្មោះសាថ្មី សំរាប់ដៃគូ និងអ្នករួមធុរៈ

ដៃគូ និងអ្នករួមធុរៈ រួមទាំងបុគ្គល ឬអង្គការណាមួយ ទាក់ទងជាមួយសមាជិក MassHealth ញឹកញាប់ និងមានសមត្ថភាពជួយគេ។ នេះរួមមានបុគ្គលិក មកពីអង្គការតាមសហគមន៍ សាខាភ្នាក់ងារ អង្គការផ្តល់សេវា និងច្រើនទៀត។

ដៃគូ និងអ្នករួមធុរៈ មានតួនាទីយ៉ាងសំខាន់ ក្នុងការជួយសមាជិក MassHealth បំពេញការចុះឈ្មោះសាថ្មីរបស់គេ។ មានជំហានដ៏រឹងមាំដែលអ្នកអាចធ្វើ ដើម្បីជួយសមាជិក MassHealth ឆ្លងកាត់នីតិវិធីការសំរេចសាថ្មី។

MassHealth បានបង្កើតធនធានខាងក្រោម ដើម្បីជួយដៃគូទាំង និងអ្នករួមធុរៈទាំងនេះ៖

| ធនធាន | ពិពណ៌នា |
|---|---|
| មគ្គុទ្ទេសក៏ MassHealth ជួយការចុះឈ្មោះសាថ្មី | ធនធានទូលំទូលាយ ដែលពន្យល់អ្នកអាចរំពឹងអ្វីខ្លះ ឋានៈជាដៃគូ ដើម្បីជួយសមាជិក MassHealth រួមទាំងរបៀបជួយគេរៀបចំ និងយល់របៀបបំពេញការចុះឈ្មោះសាថ្មី។ |
| គេហទំព័រការសំរេចសាថ្មី៖ mass.gov/masshealthrenew | ទំព័របឋម សំរាប់ព័ត៌មានការសំរេចសាថ្មី រួមទាំងធនធាន សំរាប់ប្រជាជនពិសេស, វីដេអូ, និងឯកសារជំនួយផ្សេងៗទៀត |

ជាបន្ថែមចំពោះការមើលឡើងវិញ នូវមគ្គុទ្ទេសក៍ MassHealth ជួយការចុះឈ្មោះសាថ្មី និងធនធានផ្សេងៗទៀត ក៏មានរបៀបផ្សេងទៀត ដែលអ្នកអាចជួយ។ ទាំងនេះមាន៖

1) **ការចុះឈ្មោះសំរាប់បញ្ជីអ៊ីមែល ការសំរេចសាថ្មីនៃសិទ្ធិទទួល MassHealth។** ចុះឈ្មោះដើម្បីទទួលអ៊ីមែល សំរាប់ដំណឹងថ្មីៗបំផុត និងសភាពការណ៍ ស្តីពីនីតិវិធីការសំរេចសាថ្មីរបស់ MassHealth៖ www.mass.gov/forms/masshealth-eligibility-redeterminations-email-list-sign-up

2) **ការចូលរួមក្នុងបញ្ជីអ៊ីមែល វេទិកាហ្វឹកហ្វឺនថែទាំសុខភាព ម៉ាសាជូសេត្ត (Massachusetts Health Care Training Forum, MTF) និងចូលរួមការហ្វឹកហ្វឺន។** MTF ប៉ងប្រស្រ័យទាក់ទងត្រឹមត្រូវ, ផ្តល់ព័ត៌មានទាន់ពេល ទាក់ទងនឹងក្រឹត្យក្រម MassHealth និងប្រតិបត្តិការ, កម្មវិធីរដ្ឋផ្សេងទៀត, និងកម្មវិធីជំនួយសាធារណៈ និងសេវា ចំពោះអង្គការថែទាំសុខភាពទាំងអស់ និងភ្នាក់ងារតាមសហគមន៍។ សម័យហ្វឹកហ្វឺនខាងមុខ នឹងផ្តោតលើការសំរេច សាថ្មី MassHealth។

ចុចទីនេះដើម្បីចូលរួម ក្នុងបញ្ជីអ៊ីមែល៖ www.surveymonkey.com/r/MTFListservNEW2021

សំរាប់ព័ត៌មានថែមទៀត ទស្សនាគេហទំព័រ MTF៖ https://www.masshealthmtf.org/

3) **ការក្លាយជា អ្នកប្រឹក្សាការដាក់ពាក្យសុំមានវិញ្ញាបនប័ត្រ** (**Certified Application Counselor, CAC)**។ CAC ជួយប្រជាជនដាក់ពាក្យសុំ សំរាប់អត្ថប្រយោជន៍ ធានារ៉ាប់រងសុខភាព, ចុះឈ្មោះក្នុងគំរោងសុខភាព, និង រក្សាការធានារ៉ាប់រងសុខភាព។ នៅក្នុងរដ្ឋម៉ាសាជូសេត្ត កម្មវិធី CAC គឺជាកម្មវិធីមួយរួមគ្នា បានគ្រប់គ្រងដោយ MassHealth និងបានគាំទ្រដោយ Massachusetts Health Connector។

កម្មវិធី CAC គឺជាកម្មវិធីស្ម័គ្រចិត្ត; គ្មាននរណាបង់ប្រាក់ សំរាប់ជំនួយដែលគេទទួលពី CAC។ បុគ្គលទាំងពួង មិនបាច់ត្រូវការ CAC ដើម្បីដាក់ពាក្យសុំ ឬទទួលអត្ថប្រយោជន៍ទេ ប៉ុន្តែវាគឺជាធនធានសំខាន់ សំរាប់គ្រប់ៗគ្នា ដែលមានសំណួរអំពីរបៀបដាក់ពាក្យសុំ អត្ថប្រយោជន៍ធានារ៉ាប់រងសុខភាព, ចុះឈ្មោះក្នុងគំរោងសុខភាព, និងរក្សាការធានារ៉ាប់រងសុខភាព។ បុគ្គលតែឯង មិនអាចក្លាយជា CAC បានទេ។ អង្គការរបស់អ្នកត្រូវតែ ធ្វើជា ដៃគូជាមួយ MassHealth និង Massachusetts Health Connector និងបន្ទាប់មក បុគ្គលនៅក្នុង អង្គការរបស់អ្នក អាចបានហ្វឹកហ្វឺនជា CAC។

បើសិនអ្នកមានចំណាប់ក្នុងកម្មវិធី CAC ផ្ញើអ៊ីមែលមកយើង តាមអាសយដ្ឋាន mahealthconnectortraining@massmail.state.ma.us។

## ខិត្តប័ណ្ណ, បដា, និងសំភារៈដែលសមាជិកផ្សេងទៀតប្រឈមមុខ

សូមជួយយើងផ្សាយដំណឹង អំពីការសំរេចសាថ្មី MassHealth។ ចុចទីនេះ ដើម្បីមើល និងទាញយកបដា, ខិត្តប័ណ្ណ និងព័ត៌មានសង្គម និងជាច្រើនទៀត! មានសំភារៈទូទៅ និងសំភារៈបានប៉ង សំរាប់ប្រជាជនជាក់លាក់។

សំភារៈទាំងអស់គឺមានជាភាសា អង់គ្លេស, អេស្បាញ៉ុល, ភ័ទូហ្គី, ក្រេអូល ហៃទី, វៀតណាម, ខ្មែរ, ចិន, អារ៉ាប់, និង ក្រេអូល ខាបវឺឌីន។